# គណបក្ស សិទ្ធិមនុស្ស
## HUMAN RIGHTS PARTY

បំរើ ការពារ កសាង

**កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ**

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍ ថ្ងៃសុក្រ ទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ព្រឹត្តិប័ត្រលេខ០៧៣ ឆ្នាំទី២*



| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -វិបត្តិសេដ្ឋកិច្ចធ្វើឱ្យប៉ះពាល់ដល់វិស័យកសិកម្មប្រទេសកម្ពុជា | ១ |
| -ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះជួបសកម្មជននៅខណ្ឌដង្កោ ភ្នំពេញ | ២ |
| -តើវិបត្តិសេដ្ឋកិច្ចពិភពលោកធ្វើឱ្យប៉ះពាល់អ្វីខ្លះដល់កម្ពុជា | ២ |
| -កម្ពុជានឹងអនុញ្ញាតឱ្យជនបរទេសក្លាយជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើអចលនវត្ថុ | ៣ |
| - បទពិចារណាកថាមាសនៅតែមាស | ៣ |


## វិបត្តិសេដ្ឋកិច្ចធ្វើឱ្យប៉ះពាល់ដល់វិស័យកសិកម្មប្រទេសកម្ពុជា

ប្រសាសន៍លើកឡើងរបស់លោក **សម រង្ស៊ី** ប្រធានគណបក្សសមរង្ស៊ី និងលោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស ដែលលោកបានថ្លែងនៅក្នុងសន្និសីទសារពត៌មានទាក់ទងនឹងវិបត្តិសេដ្ឋកិច្ច និងសំណើររួមរវាងគណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ី ឱ្យចាត់វិធានការសមស្រប និងជាបន្ទាន់ដើម្បីជួយដល់ប្រជាពលរដ្ឋខ្មែរដែលកំពុងរងគ្រោះ នៃតំលៃកសិផលនៅលើទីផ្សារ នៅឯទីស្នាក់ការកណ្តាលគណបក្សសមរង្ស៊ីកាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩នេះ ។ លោក **សម រង្ស៊ី** មានប្រសាសន៍ថា វិបត្តិសេដ្ឋកិច្ចបានធ្វើឱ្យកសិផលរបស់ប្រជាពលរដ្ឋខ្មែរ នៅលើទីផ្សារមានតំលៃធ្លាក់ចុះដូចជា ពោត សណ្តែក ស្រូវ អង្ករ ដំឡូងជាដើម ហើយលោកបានស្នើឱ្យរដ្ឋាភិបាលចាត់វិធានការជាបន្ទាន់ ដើម្បីជួយបញ្ចៀសកុំឱ្យធនាគារ និងម្ចាស់បំណុលផ្សេងៗរឹបអូសយកដីធ្លីរបស់ប្រជាកសិករទាំងនោះ ពីព្រោះដីធ្លីទាំងនោះបានដាក់បញ្ចាំ ។ បច្ចុប្បន្នស្ថានការណ៍សេដ្ឋកិច្ចនៅកម្ពុជាមិនអនុញ្ញាត ដល់ប្រជាពលរដ្ឋសងបំណុលរបស់ពួកគាត់បានទេ អាស្រ័យដោយតំលៃកសិផលនៅលើទីផ្សារបានធ្លាក់ចុះយ៉ាងខ្លាំង និងប្រាក់ចំណូលរបស់ពួកគាត់ក៏ធ្លាក់ចុះទៅតាមទីផ្សារផងដែរ ។ លោកបន្តទៀតថា នៅប្រទេសដទៃគេមានវិធានការទប់ស្កាត់កុំឱ្យធនាគារ និងម្ចាស់បំណុលដកហូតយកដីធ្លីរបស់កសិករ ដែលបានយកដីធ្លីទាំងនោះទៅដាក់បញ្ចាំ ។ នៅក្នុងសន្និសីទនោះដែរ លោក **សម រង្ស៊ី** បានថ្លែងសង្កត់ធ្ងន់ថា លោកស្នើឱ្យប្រទេសផ្តល់ជំនួយឱ្យប្រទេសកម្ពុជា សូមថ្កោលទោស និងផ្តន្ទាទោសព្រមទាំងដាក់ទណ្ឌកម្ម ចំពោះអ្នកដឹកនាំប្រទេសណាដែលមានឈ្មោះនៅក្នុងរបាយការណ៍ Global Witness ប្រទេសជាមិត្តទាំងអស់ត្រូវចាត់វិធានការ៣យ៉ាង គឺទី១: កុំឱ្យផ្តល់វិសា និងទិដ្ឋាការចូលទៅប្រទេសដទៃ ដូចជាប្រទេសផ្តល់ជំនួយ និងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ ។ វិធានការទី២ : សូមរឹងអូសនូវទ្រព្យសម្បត្តិដែលជនពុករលួយទាំងនោះបានយកទៅតំកល់ទុកនៅធនាគារ ដើម្បីបង្ការទុកសំរាប់សងប្រជាពលរដ្ឋនៅថ្ងៃខាងមុខ ។ រីឯវិធានការទី៣ : សូមឱ្យប្រទេសមួយចំនួនហាមឃាត់ចំពោះក្រុមហ៊ុនណាដែលមានភាគហ៊ុនជាមួយគ្រួសារថ្នាក់ដឹកនាំជាម្ចាស់ភាគហ៊ុនជាដើម ។ ម្យ៉ាងវិញទៀតវិបត្តិសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរទៅៗដែលកើតមានស្ទើរគ្រប់ប្រទេស ហើយស្ថានការណ៍នេះ

អ្នកដឹកនាំប្រទេសនានាគេព្រួយបារម្ភទូទាំងពិភពលោក ចំឡែកតែរដ្ឋាភិបាលខ្មែរបែរជាព្រងើយកន្តើយទៅវិញ ។

ចំណែកលោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ថាវិបត្តិសេដ្ឋកិច្ចនៅប្រទេសកម្ពុជា គឺជាគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរសំរាប់ជាតិ និងប្រជាពលរដ្ឋ ព្រោះប្រជាកសិករនាឆ្នាំនេះកើតមាននូវវិបត្តិដោយសារផលិតផលលក់មិនចេញ តែបើលក់ចេញគឺស្ថិតក្នុងតំលៃទាបដែលមិនអាចសល់ និងសងទៅម្ចាស់បំណុលរួចទៀតផង ។ សព្វថ្ងៃនេះកសិករនៅតាមបណ្តាខេត្តកំពុងតែយំស្រែកដោយកសិផលរបស់ពួកគាត់ ដូចជា ស្រូវ សណ្តែក ដំឡូង ពោត គ្មានទីផ្សារសំរាប់លក់ ម្យ៉ាងទៀតប្រជាពលរដ្ឋទាំងនោះ ខ្ចីលុយពីធនាគារដែលមានការប្រាក់ខ្ពស់ ហើយពួកគាត់ក៏បានដាក់បញ្ចាំប្លង់ដីធ្លី ផ្ទះសំបែង ។ ប្រសិនបើគ្មានប្រាក់សងនោះនឹងត្រូវគេរឹបអូសយកដីធ្លី និងផ្ទះសំបែងរបស់ពួកគាត់ជាមិនខាន ។

## ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ចុះជួបសកម្មជននៅខណ្ឌដង្កោ រាជធានីភ្នំពេញ

នៅព្រឹកថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ នេះ លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស បានជួបសំណេះសំណាលជាមួយនឹងសកម្មជន និងអ្នកគាំទ្រគណបក្សសិទ្ធិមនុស្សនៅតាមខណ្ឌដង្កោ រាជធានីភ្នំពេញ ។ បើយោងតាមសកម្មជនគណបក្សសិទ្ធិមនុស្សប្រចាំខណ្ឌដង្កោបានឱ្យដឹងថា កិច្ចសំណេះសំណាលរវាងប្រធានគណបក្សសិទ្ធិមនុស្សជាមួយសកម្មជន ដែលមកពីសង្កាត់ទាំង១៥ ក្នុងខណ្ឌដង្កោប្រារព្ធធ្វើនៅភូមិគោកខ្សាច់ និងសង្កាត់ភ្លើងឆេះរទេះ ក្នុងលក្ខណៈគ្រួសារតែមួយ ហើយក្នុងនោះក៏មានការរៀបចំបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សខណ្ឌដង្កោផងដែរ ហើយសកម្មជនរូបនោះ បានបញ្ជាក់ថាគោលជំហររបស់សកម្មជនដទៃទៀតនៅក្នុងខណ្ឌដង្កោ គឺមានការស្មោះស្ម័គ្រអស់ពីចិត្តដើរលើមាគ៌ានយោបាយ និងដង្ហែរតាមថ្នាក់ដឹកនាំរបស់គណបក្សសិទ្ធិមនុស្ស ។

លោក **កឹម សុខា** មានប្រសាសន៍ទៅកាន់បងប្អូនសកម្មជន និងអ្នកគាំទ្រដែលបានចូលរួមថា ចាប់តាំងពីគណបក្សបង្កើតឡើងហើយរៀបចំសមាជ គឺមានប្រជាពលរដ្ឋចូលរួមយ៉ាងច្រើនកុះកររាប់សិបម៉ឺននាក់ដែលពីមុនធ្លាប់មាន ហើយមានតែគណបក្សសិទ្ធិមនុស្សមួយតែប៉ុណ្ណោះ ។ ក្រោយពីសមាជថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៧ គណបក្សសិទ្ធិមនុស្សទទួលបាននូវប្រជាប្រិយភាពជាច្រើន តែក្រោយមកក៏ធ្លាក់ប្រជាប្រិយភាពដោយសារមានការមួលបង្កាច់ជាច្រើនមកលើគណបក្ស និងថ្នាក់ដឹកនាំគណបក្សទៀតផង ។

## តើវិបត្តិសេដ្ឋកិច្ចពិភពលោកធ្វើឱ្យប៉ះពាល់អ្វីខ្លះដល់កម្ពុជា

បើតាមទស្សនៈវិស័យរបស់លោក **គៀត សុគន្ធ** អនុប្រធានគណបក្សសិទ្ធិមនុស្ស វិបត្តិសេដ្ឋកិច្ចពិភពលោកធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បណ្តាប្រទេសតូចតាច តួយ៉ាងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជាជាដើម ។ មិនតែប៉ុណ្ណោះលោកមើលឃើញថា វិបត្តិសេដ្ឋកិច្ចពិភពលោក ដែលធ្វើឱ្យប៉ះពាល់ដល់ប្រទេសកម្ពុជាជាសំខាន់នោះគឺ កសិផលរបស់កសិករខ្មែរលក់មិនដាច់ ឬលក់បានក្នុងតំលៃថោក ដូច្នេះហើយធ្វើឱ្យពួកគាត់ខ្វះខាតលុយកាក់សងទៅធនាគារ ។ ប្រសិនបើពួកគាត់ខ្វះលុយសំរាប់បង្វិលសងទៅធនាគារគេនឹងរឹបអូសយកដីស្រែចំការ ប្លង់ដី ផ្ទះសំបែងទៅតាមកិច្ចសន្យាដែលបានកំណត់ ។ លោកបន្តទៀតថា បញ្ហាវិបត្តិហេរិញ្ញវត្ថុនៅលើសកលលោកនេះ រដ្ឋាភិបាលប្រទេសនានា ក៏ដូចជារដ្ឋាភិបាលប្រទេសថៃគេមានវិធានការប្រកបដោយតម្លាភាព ក្នុងការជួយដល់ប្រជាពលរដ្ឋ ។ ករណីប្រជាពលរដ្ឋខ្វះប្រាក់សងទៅធនាគាររដ្ឋាភិបាលត្រូវតែជួយធ្វើអន្តរាគមន៍ ដើម្បីពន្យារពេលនៃការសងប្រាក់ និងជួយឱ្យប្រជាពលរដ្ឋទាំងនោះខ្ចីប្រាក់បន្តទៀត ការដែលធ្វើយ៉ាងនេះក្នុងទិសដៅកុំឱ្យកសិករ បាត់បង់ការងាររបស់ខ្លួនបន្តទៀត ។

វិបត្តិសេដ្ឋកិច្ច មិនមែនធ្វើឱ្យប៉ះពាល់ដល់កសិករតែមួយប៉ុណ្ណោះទេសូម្បីតែកម្មករក៏ប្រឈមមុខនឹងការបាត់បង់ការងារធ្វើ ហើយក៏ធ្វើឱ្យគេយំស្រែកអស់សង្ឃឹមថា តើរដ្ឋាភិបាលមានគំរោង

ជួយដល់កម្មករដែរឬទេ ? រដ្ឋាភិបាលខ្មែរគួរតែមានវិធានការឱ្យច្បាស់លាស់ហើយកំណត់ថា តើមានថវិកាប៉ុន្មានលានជួយផ្នែកអ្វីខ្លះដើម្បីកុំឱ្យបងប្អូនដែលកំពុងជួបប្រទះ នឹងវិបត្តិសេដ្ឋកិច្ចមានកង្វល់ មានទុក្ខសោកឥតឈប់ឈរ ។ មួយវិញទៀតបើយយើងមិនរិះរកវិធានការជួយដោះស្រាយផងទេ ហើយបែរជាបណ្តែតបណ្តោយឱ្យបញ្ហាចេះតែធ្លាក់ចុះទៅៗ ប្រជាពលរដ្ឋដោះស្រាយបញ្ហានេះដោយខ្លួនឯង ចំណែករដ្ឋាភិបាលមិនជួយអន្តរាគមន៍នោះ បញ្ហាសង្គមនឹងកើតមានឡើង ។ ទាក់ទងនឹងវិបត្តិសេដ្ឋកិច្ចដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ជាពិសេសតំលៃកសិផលរបស់កសិករចុះថោក គណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ី បានដាក់សំណើរទៅរដ្ឋាភិបាលតាមរយៈលោក **ហេង សារិន** ប្រធានរដ្ឋសភាដើម្បីឱ្យរដ្ឋាភិបាលចាត់វិធានការសមស្របជាបន្ទាន់ក្នុងការជួយសង្គ្រោះកសិករ ដែលកំពុងរងគ្រោះដោយការធ្លាក់ចុះយ៉ាងខ្លាំងនៃតំលៃផលិតផលកសិកម្ម ហើយមានជំពាក់បំណុលគេយ៉ាងច្រើនឱ្យរួចផុតពីការរឹបអូសដីធ្លី ពីសំណាក់ធនាគារ និងម្ចាស់បំណុល ។

## កម្ពុជានឹងអនុញ្ញាតឱ្យជនបរទេស ក្លាយជាម្ចាស់កម្មសិទ្ធិស្របច្បាប់ លើអចលនវត្ថុ

លោក **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងពត៌មាន និងជាអ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជាត្រូវបានកាសែត The Cambodia Daily ដកស្រង់សំដីថា *រដ្ឋាភិបាលកំពុងតែចាត់វិធានការយ៉ាងសកម្មដើម្បីអនុញ្ញាតឱ្យជនបរទេស ធ្វើជាម្ចាស់ទ្រព្យសម្បត្តិនៅក្នុងប្រទេសកម្ពុជា ដោយពេលនេះក្រសួងនគររូបនីយកម្មកំពុងតែព្រាងគំរោងច្បាប់* ។ ក្នុងកិច្ចប្រឹងប្រែងដែលលោក **ខៀវ កាញារីទ្ធ** បានមានប្រសាសន៍ថានឹងបង្កើនភាពងាយស្រួល នៃការធ្វើធុរកិច្ចក្នុងប្រទេសកម្ពុជា ជនបរទេសនឹងត្រូវអនុញ្ញាតឱ្យទិញកម្មសិទ្ធិ១00% សំរាប់ផ្ទះល្វែង ឬខុនដូបាន ។ លោកបានមានប្រសាសន៍ថា ទោះជាយ៉ាងក្តីដីនឹងនៅតែត្រូវហាមប្រាមសំរាប់អ្នកទិញបរទេស ។ លោកមានប្រសាសន៍ នៅក្នុងកិច្ចសំភាសន៍មួយនៅឯសន្និសីទស្តីអំពីធនាគារនៅកម្ពុជាឆ្នាំ២០០៩ ក្នុងរាជធានីភ្នំពេញថា ”ជនបរទេសនឹងអាចផ្តល់កម្មសិទ្ធិនោះ ជាកេរតំណែលដល់កូនៗរបស់ពួកគេយើងរៀបចំកម្មសិទ្ធិនេះរួចហើយ ។ ប៉ុន្តែយើងមិនផ្លាស់ប្តូរច្បាប់ភូមិបាលទេ ហើយនៅពេលអ្នកមានផ្ទះល្វែងមួយ វាមិនមែនជាដីឡើយ មិនតែប៉ុណ្ណោះក្រសួងរៀបចំដែនដីកំពុងតែពិភាក្សាយ៉ាងសកម្មអំពីបញ្ហានេះ ។ បច្ចុប្បន្ននេះ ជនបរទេសគ្រាន់តែអាចជួលផ្ទះល្វែង ឬខុនដូរយៈពេល៩៩ឆ្នាំប៉ុណ្ណោះ ដែលរយៈពេលច្រើនឆ្នាំហើយរដ្ឋាភិបាលមានទំនាស់ផ្ទៃក្នុង ថាតើច្បាប់ភូមិបាលឆ្នាំ២០០១ ដែលហាមប្រាមកម្មសិទ្ធិដីធ្លីបរទេស អាចអនុញ្ញាតឱ្យជនបរទេសមានទីកន្លែងនៅលើដីឬយ៉ាងណា ។

លោក **លឹម វ៉ន** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីទទួលបន្ទុកកម្មសិទ្ធិដីធ្លី បានមានប្រសាសន៍ថា ពេលនេះក្រសួងរបស់លោកកំពុងតែសិក្សាច្បាប់ភូមិបាល ដើម្បីរកវិធីសំរាប់ជនបរទេសធ្វើជាម្ចាស់ផ្ទះល្វែង ឬខុនដូ ។ លោកមានប្រសាសន៍ទៀតថា នាយកដ្ឋានច្បាប់របស់ក្រសួងពេលនេះកំពុងសិក្សាអំពីច្បាប់នេះ ប៉ុន្តែមិនដឹងថាពេលណាច្បាប់នោះបញ្ចប់ទេ ។ យើងត្រូវការស្វែងរកច្រកចូលសំរាប់ជនបរទេស ដែលអាចអនុញ្ញាតឱ្យពួកគេមានតែអគារប៉ុណ្ណោះ ។

លោក **រ៉ុង ឈុន** ប្រធានសមាគមនគ្រូបង្រៀនឯករាជ្យនៅកម្ពុជាបានបញ្ជាក់ថា លោកមិនទាន់ឃើញច្បាប់ ឬអនុក្រឹត្យណាមួយអនុញ្ញាត ឱ្យជនបទេសមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុនៅក្នុងប្រទេសកម្ពុជានៅឡើយទេ ។ ចំពោះគំរោងដែលរដ្ឋាភិបាល ចង់អនុញ្ញាតឱ្យជនបរទេសមានសិទ្ធិធ្វើជាកម្មសិទ្ធិករនោះលោកមិនដឹងថា រដ្ឋាភិបាលពឹងផ្អែកទៅលើមូលដ្ឋានអ្វីនោះទេ ប្រសិនបើអត់មានមូលដ្ឋានអ្វីជាក់លាក់ ឬប្រាក់តំកល់ណាមួយនោះទេ យើងមិនគួរផ្តល់កម្មសិទ្ធិជូនជនបរទេសទាំងនោះទេ។

## បទវិចារណកថា មាសនៅតែមាស

ចាប់តាំងតែពីគណបក្សសិទ្ធិមនុស្សចាប់កំណើតរហូតមកទល់ពេលបច្ចុប្បន្ននេះ គណបក្សសិទ្ធិមនុស្សត្រូវបានហ្វូងមនុស្សអគតិដែលមានចរិតជាសត្វ ដែលបានពោលពាក្យបង្កាច់បង្ខូចឈ្មោ

នីសមិនឈប់ឈរ ។ ខ្លះថាគណបក្សសិទ្ធិមនុស្សជាអាយ៉ងរបស់គណបក្សកាន់អំណាច ខ្លះថាគណបក្សសិទ្ធិមនុស្ស ជាគណបក្សដែល **ហ៊ុន សែន** បង្កើតឡើង និងទទួលលុយពី **ហ៊ុន សែន** ដើម្បីបំបែកសំឡេងក្រុមអ្នកប្រជាធិបតេយ្យ ។ តែពាក្យដែលពោលខាងលើនេះបានរលុបទៅវិញនៅថ្ងៃទី២៤-២៥ ខែកញ្ញា ឆ្នាំ២០០៨ ជាថ្ងៃដែលគណបក្សកាន់អំណាច លើកយកថ្ងៃនោះជាថ្ងៃចូលស្បថ និងប្រកាសសុពលភាពសមាជិករដ្ឋសភា ព្រមទាំងគំរាមថាបើគណបក្សណាមិនចូលរួមក្នុងថ្ងៃនោះទេអាសនៈ របស់គណបក្សនោះត្រូវគេយកទៅឱ្យគណបក្សផ្សេងៗទៀត ។ ទោះបីជាបានទទួលពាក្យគំរាមបែបនេះក៏ជំហរដ៏រឹងប៉ឹង នៃគណបក្សសិទ្ធិមនុស្សពុំប្រែប្រួលឡើយ ដោយយើងនៅតែពុំព្រមចូលដដែលក្នុងន័យគាំទ្រសំឡេងប្រជាពលរដ្ឋខ្មែរដែលជាម្ចាស់ឆ្នោត ។

បច្ចុប្បន្នក៏ដូចជាពីអតីតកាលកន្លងទៅថ្មីៗនេះ ជំហរសម្ព័ន្ធភាព ឬការរួបរួមរវាងគណបក្សក្រៅរដ្ឋាភិបាល ទាំងអស់របស់គណបក្សសិទ្ធិមនុស្សនៅតែប្រកាន់ខ្ជាប់ឥតមានងាករេឡើយ ជាពិសេសជាមួយគណបក្សសមរង្ស៊ី ។ ជាបឋមហើយឈានទៅរួបរួមជាមួយគណបក្សផ្សេងៗនៅតែឋិតនៅក្នុងគោលនយោបាយ និងគោលជំហររបស់គណបក្សសិទ្ធិមនុស្ស ក៏ដូចជាឆន្ទៈរបស់សមាជិក សមាជិកាគ្រប់លំដាប់ថ្នាក់របស់គណបក្សសិទ្ធិមនុស្ស និងរបស់ប្រជាពលរដ្ឋខ្មែរដែលចង់ឱ្យប្រទេសមានការផ្លាស់ប្តូរ និងមានការអភិវឌ្ឍន៏ប្រកបដោយចីរភាព ។

ផ្ទុយពីបំណងរបស់ប្រជាពលរដ្ឋខាងលើ សមាសភាពអមិត្តដែលជាខ្ញុំកញ្ជះរបស់ពួកជនពុករលួយដែលរស់បាន ព្រោះតែចេះបក់បន្ទុយ និងលិទកំអួតរបស់ចៅហ្វាយ ហើយស្រវឹងនឹងកំអួតនោះតែងតែព្រួសពាក្យដដែលៗ ថាគណបក្សសិទ្ធិមនុស្សជិតស្លាប់ហើយបានជាស្រវាអោបគណបក្សផ្សេងដើម្បីបន្តជីវិតរបស់ខ្លួន ។

ពាក្យល្ងីល្ងើរបស់ក្រុមស្រវឹងនឹងកំអួតនោះ ពិតជាពុំមានប្រជាពលរដ្ឋខ្មែរណាម្នាក់ជឿឡើយ ព្រោះគេស្គាល់ក្រយៅជននោះច្បាស់លាស់ថា ពួកនោះមានកំលាំងព្រួសបានក៏ព្រោះតែកំអួតចៅហ្វាយរបស់ខ្លួនតែប៉ុណ្ណោះ បើចៅហ្វាយរបស់ខ្លួនលែងក្អួតឱ្យលិទគេនឹងលែងព្រួស ហើយដាច់ខ្យល់ស្លាប់ភ្លាម ។

ជាមួយនេះគណបក្សសិទ្ធិមនុស្សសូមបញ្ជាក់ចំពោះប្រជាពលរដ្ឋម្ចាស់ឆ្នោតជ្រាបថា ការដែលគណបក្សសិទ្ធិមនុស្ស មានបំណងរួបរួមជាមួយគណបក្សផ្សេងៗ ជាពិសេសជាមួយគណបក្សសមរង្ស៊ីនោះ គឺយើងគោរពតាមឆន្ទៈប្រជាពលរដ្ឋ ទាំងក្នុង និងក្រៅប្រទេសដែលចង់ឃើញឱ្យមានការរួបរួមគ្នានេះ ហើយគណបក្សសិទ្ធិមនុស្សក៏ពុំស្លាប់ដែរ ទោះបីជាមិនបានរួបរួមក៏ធ្វើសម្ព័ន្ធភាពជាមួយ នឹងគណបក្សផ្សេងៗក៏ដោយ ។ ទន្ទឹមនឹងនេះក៏ពុំមែនបញ្ជាក់ថា គណបក្សសិទ្ធិមនុស្សមានតែ៣អាសនៈ ហើយខ្សោយពុំអាចធ្វើអ្វីបាននោះឡើយ តែផ្ទុយទៅវិញគឺជាការលះបង់របស់គណបក្សសិទ្ធិមនុស្ស និងអ្នកដឹកនាំ គណបក្សសិទ្ធិមនុស្សដែលយកប្រយោជន៏ប្រជាពលរដ្ឋជាចម្បងជាងប្រយោជន៏ស្ទួនតួ ។

ដូច្នេះទោះបីក្រុមពួកស្រវឹងនឹងកំអួតទាំងនោះ ព្រួសទាល់តែស្លាប់ ក៏មិនអាចធ្វើឱ្យស្រអាប់ពណ៌ដ៏ភ្លឺថ្លា របស់គណបក្សសិទ្ធិមនុស្ស ព្រោះថាមាសសុទ្ធមិនដែលខ្លាចភ្លើង ហើយមាសនៅតែជាមាសដដែល ទោះបីគេយកទៅកែច្នៃ ឬ ធ្វើជាអ្វីក៏ដោយ ។ ដូចពាក្យដែលខ្មែរនិយមពោលតៗថា " **ឆ្កែចេះតែព្រួស មនុស្សចេះតែដើរទៅមុខជាដរាប** " ។


| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| **លោក** | **ម៉ី សាន** | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| **កញ្ញា** | **គង់ វណ្ណា** | ទូរស័ព្ទលេខ: ០១២ ៨៦៩ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |


**វិបត្តិសេដ្ឋកិច្ចពិភពលោកធ្វើឱ្យប៉ះពាល់ដល់វិស័យដីធ្លីនៅកម្ពុជា !**